# របាយការណ៍សង្ខេបស្តីពីការវាយតម្លៃបឋម

## សេចក្តីព្រាងអនុក្រឹត្យស្តីពីអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិក សម្រាប់សិស្ស និស្សិតសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ

ក្រសួង: អប់រំ យុវជន និងកីឡា

លេខយោង: ០០០០០២០

កាលបរិច្ឆេទចាប់ផ្តើម : ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤

កាលបរិច្ឆេទបញ្ចប់ : ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៤

អនុក្រឹត្យនេះ មានគោលបំណងបង្កើនសុខុមាលភាពនិស្សិតដែលទទួលបានប្រាក់អាហារូបករណ៍និងលើកទឹកចិត្តក្នុងការសិក្សារបស់និស្សិតទាំងនោះ។ ដើម្បីសម្រេចបានគោលបំណងនេះ បញ្ញត្តិកម្មនេះត្រូវបានបង្កើតឡើងដើម្បីបង្កើនប្រាក់ឧបត្ថម្ភប្រចាំខែដល់សិស្ស និស្សិត និងបុគ្គលិកអប់រំ តាមគ្រឹះស្ថានសិក្សាសាធារណៈនានា ឲ្យស្របតាមការវិវត្តនៃសេដ្ឋកិច្ចជាតិនាពេលបច្ចុប្បន្ន។ កន្លងមក ការផ្តល់អាហារូបករណ៍ និងប្រាក់ឧបត្ថម្ភជីវភាពអន្តេវាសិកប្រចាំខែត្រូវបានអនុវត្តតាមអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិក ដែលមានកម្រិតទាបពេក មិនមានការទាក់ទាញដល់អ្នកសិក្សានាពេលបច្ចុប្បន្ន។ ថវិកាដែលត្រូវប្រើប្រាស់ដើម្បីអនុវត្តអនុក្រឹត្យនេះជាបន្ទុកថវិការបស់រដ្ឋ។

ការសិក្សាវាយតម្លៃលើផលប៉ះពាល់នៃគម្រោងដំឡើងប្រាក់អាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកសម្រាប់សិស្ស និស្សិតសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ ត្រូវបានធ្វើឡើងដោយផ្តោតសំខាន់លើជម្រើស៣ មានដូចខាងក្រោម៖

១-ជម្រើសទី១ : បន្តអនុវត្តអនុក្រឹត្យលេខ១៨ ដដែល។

២-ជម្រើសទី២ : ក្រសួងអប់រំ យុវជន និងកីឡា អនុវត្តអនុក្រឹត្យថ្មីនេះ ប៉ុន្តែក្រសួងផ្សេងទៀតបន្តអនុវត្តអនុក្រឹត្យលេខ១៨ដដែល។

៣-ជម្រើសទី៣ : អនុវត្តអនុក្រឹត្យថ្មីនេះ គ្រប់ក្រសួងពាក់ព័ន្ធទាំង៦។

ផ្អែកតាមការវិភាគលើបន្ទុកចំណាយថវិការដ្ឋនៃជម្រើសទាំង៣ ខាងលើនេះ បង្ហាញថាជម្រើសទី១ មានបន្ទុកចំណាយថវិការដ្ឋចំនួន ១.៩២០.៣១៤.២០០រៀល តិចជាងជម្រើសទី២ ដែលមានបន្ទុកចំណាយថវិការដ្ឋចំនួន ៦.៧៥១.៤២៧.២០០រៀល ក៏ប៉ុន្តែ បន្ទុកចំណាយរបស់ជម្រើសទី២ នេះ តិចជាងជម្រើសទី៣ ដែលមានបន្ទុកចំណាយថវិការដ្ឋចំនួន ៨.៣៩៨.៣៧៧.២០០រៀល ដែលរដ្ឋមានលទ្ធភាពក្នុងការចំណាយ។ ទោះជាជម្រើសទី៣ មានបន្ទុកចំណាយខ្ពស់ជាងជម្រើស២ ក៏ដោយ ក៏ការវិភាគលើផលចំណេញនៃជម្រើសទាំង៣ នេះ បានបង្ហាញថាជម្រើសទី៣ ផ្តល់ផលចំណេញផ្នែកសេដ្ឋកិច្ច សង្គម (មានសមធម៌ក្នុងចំណោមសិស្សនិស្សិតនៃគ្រឹះស្ថានសិក្សាក្រោមក្រសួងនានាដែលត្រូវទទួលរបបអាហារូបករណ៍) ច្រើនជាងគេ ក្នុងចំណោមជម្រើសទាំង៣នេះ ដោយមានចំនួនសិស្ស និស្សិតចំនួន ២៨ ០៥៩នាក់ នឹងត្រូវទទួលបានប្រាក់អាហារូបករណ៍តាមរបបថ្មីនេះ ច្រើនជាងជម្រើសទី២ ចំនួន ១៥ ៤៧៥នាក់។

ដោយឈរលើមូលដ្ឋាននៃផលចំណេញជាចម្បង ជម្រើសទី៣ គួរត្រូវបានជ្រើសរើសក្នុងការដោះស្រាយបញ្ហាដូចបានលើកឡើងខាងលើ។

# របាយការណ៍ស្ដីពីការវាយតម្លៃបឋម

## សេចក្ដីព្រាងអនុក្រឹត្យស្ដីពីអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្ដេវាសិក សម្រាប់សិស្ស និស្សិតសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ

ក្រសួង: អប់រំ យុវជន និងកីឡា

លេខយោង: ០០០០០២០

កាលបរិច្ឆេទចាប់ផ្ដើម : ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤

កាលបរិច្ឆេទបញ្ចប់ : ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៤

ទំនាក់ទំនង :

| | ឈ្មោះ | លេខទូរស័ព្ទ | អ៊ីមែល |
|---|---|---|---|
| IA-ទទួលបន្ទុក | លោក ស៊ន សេងហុក | ០១២ ៥៨៦ ៥៥៤ | hoklaw@gmail.com |
| IA-ជំនួស | លោក ប៉ូវ វី | ០១២ ៩៨៥ ៨៣២ | povvy2002@yahoo.com |
| IA-ជំនួស | លោកស្រី ហេង ងួនឡាង | ០១១ ៨៥៦ ៥២៧ | ayuthyaly@gmail.com |
| IA-ជំនួស | លោក សឹង ប្រាក់ | ០១២ ៩៥៧ ៥០៧ | prak_soeung@yahoo.com |
| ORIA-ទទួលបន្ទុក | ល.ជ ស៊ាង សុផល្លា | ០១២ ៦៦៥ ២០១ | seangsophalla@yahoo.com |
| ORIA-ជំនួស | លោកស្រី ស៊ីម រ័ត្នថា | ០១២ ៩៤៨ ៨៦៥ | simrotha80@yahoo.com |

### អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

អនុក្រឹត្យនេះមានគោលបំណងបង្កើនសុខុមាលភាពនិស្សិតដែលទទួលបានប្រាក់អាហារូបករណ៍ និងលើកទឹកចិត្តក្នុងការសិក្សារបស់និស្សិតទាំងនោះ។ ដើម្បីសម្រេចបានគោលបំណងនេះ បញ្ញត្តិកម្មនេះត្រូវបានបង្កើតឡើងដើម្បីបង្កើនប្រាក់ឧបត្ថម្ភប្រចាំខែដល់សិស្ស និស្សិត និង បុគ្គលិកអប់រំ តាមគ្រឹះស្ថានសិក្សាសាធារណៈនានា ក្នុងក្របខ័ណ្ឌក្រសួងអប់រំ យុវជន និងកីឡា ឲ្យស្របតាមការវិវត្តនៃសេដ្ឋកិច្ចជាតិពេលបច្ចុប្បន្ន(កម្រិតថ្លៃទំនិញ និងទំហំកំណើនសេដ្ឋកិច្ច)។ កន្លងមក ការផ្ដល់អាហារូបករណ៍ និងប្រាក់ឧបត្ថម្ភប្រចាំខែបានអនុវត្តតាមអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៧ ស្ដីពីអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្ដេវាសិក ដែលមានកម្រិតទាបពេក មិនមានការទាក់ទាញដល់អ្នកសិក្សានាពេលបច្ចុប្បន្ន។ ថវិកាដែលត្រូវប្រើប្រាស់ដើម្បីអនុវត្តអនុក្រឹត្យនេះជាបន្ទុកថវិការបស់រដ្ឋ។

ប្រាក់អាហារូបករណ៍ប្រចាំខែនិងចំនួនសិស្ស និស្សិតដែលត្រូវទទួលបាន មានដូចខាងក្រោម ៖

- ក្រោយបរិញ្ញាបត្រ : អាហារូបករណ៍ប្រចាំខែ ៨០.០០០ រៀល បានទទួលចំនួន ២៥% (ពីមុន ១២.០០០រៀល បានទទួលចំនួន៥០%)
- បរិញ្ញាបត្រ : អាហារូបករណ៍ប្រចាំខែ ៤៥.០០០ រៀល បានទទួលចំនួន ១០% (ពីមុន

| |
|---|
| ១០.០០០រៀល បានទទួលចំនួន១០%)<br>• កម្រិតមធ្យមសិក្សាឯកទេស : អាហារូបករណ៍ប្រចាំខែ ៩០.០០០ រៀល បានទទួលចំនួន ៣០% (ពីមុន ៩.០០០រៀល បានទទួលចំនួន៣០%)<br>• កម្រិតបឋមសិក្សាឯកទេស : អាហារូបករណ៍ប្រចាំខែ ៣០.០០០ រៀល បានទទួលចំនួន ៣៥% (ពីមុន ៨.០០០រៀល បានទទួលចំនួន៣៥%) |

ប្រភេទបញ្ញត្តិកម្ម

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☑ | ☐ | ☐ | ☐ | ☐ |

## ១. **ការកំណត់បញ្ហា**

| បញ្ហាសំខាន់ៗ | បញ្ញត្តិកម្មនេះមានបំណងដោះស្រាយ (*មែន ឬមិនមែន*) | ភស្តុតាង/ភាពជាក់ស្តែង (សូមភ្ជាប់កំណត់សម្គាល់ប្រសិនបើចាំបាច់) |
|---|---|---|
| សុខភាព និងសុវត្ថិភាពសាធារណៈ<br>ការការពារ និងអភិរក្សបរិស្ថាន | មិនមែន<br>មិនមែន | |
| សមធម៌យេនឌ័រ និងសង្គម និងការអភិរក្សវប្បធម៌ | មិនមែន | |
| ការប្រកួតប្រជែង | មិនមែន | |
| ការប្រមូលព័ត៌មាន | មិនមែន | |
| អនុលោមតាមកិច្ចព្រមព្រៀង WTO និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត | មិនមែន | |

*ប្រសិនបើមានបញ្ហាផ្សេងទៀត សូមអធិប្បាយ និងផ្តល់ភស្តុតាង*

| |
|---|
| អាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកដែលបានផ្តល់កន្លងមកនៅមានកម្រិតទាបពេកបើធៀបនឹងការវិវត្តនៃសេដ្ឋកិច្ចបច្ចុប្បន្ន។ នៅក្នុងអនុក្រឹត្យលេខ១៨ ដែលចេញកាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៧ បានផ្តល់អាហារូបករណ៍ដល់និស្សិតឧត្តមសិក្សាក្នុង១ខែ ១០ ០០០រៀល។ ប្រាក់អាហារូបករណ៍ចំនួន ១០ ០០០រៀល ក្នុងឆ្នាំ១៩៩៧ អាចជួយរួមចំណែកលើកទឹកចិត្តខ្លះៗដល់សិស្ស និស្សិត ក៏ប៉ុន្តែពេលបច្ចុប្បន្ននេះ ចំនួនទឹកប្រាក់នេះមានកម្រិតទាបពេកក្នុងការលើកទឹកចិត្តអ្នកសិក្សា។ ម្យ៉ាងវិញទៀត អនុក្រឹត្យលេខ១៨ នេះ មានអាយុកាល១៧ឆ្នាំ ហើយត្រូវបានអនុវត្តដោយពុំមានការកែប្រែអ្វីសោះ។ |

លិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ដែលពាក់ព័ន្ធ ឬប្រហាក់ប្រហែល។

| |
|---|
| ១. អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិក<br>២. ច្បាប់ស្តីពីការអប់រំ ឆ្នាំ២០០៧ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧<br>៣. អនុក្រឹត្យលេខ១០២ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ ស្តីពីការកំណត់ចំណាយដោយឡែកសម្រាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាពនៅក្រសួងអប់រំ យុវជន និងកីឡា<br>៤. អនុក្រឹត្យលេខ១០ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេស |

ចូរបញ្ជាក់ថា តើហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តទាំងនេះមិនទាន់គ្រប់គ្រាន់?

| |
|---|
| ច្បាប់និងអនុក្រឹត្យខាងលើមិនបានចែងច្បាស់ស្តីពីការផ្តល់អាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពដល់សិស្ស និស្សិត។ ក៏ប៉ុន្តែអនុក្រឹត្យលេខ១៨ បានចែងច្បាស់អំពីការផ្តល់អាហារូបករណ៍ តែអត្រាប្រាក់អាហារូបករណ៍នៅមានកម្រិតទាបពេក បើធៀបនឹងការវិវត្តនៃសេដ្ឋកិច្ចជាតិនិងអត្រាអតិផរណា នាពេលបច្ចុប្បន្ន។ |

តើយើងពិតជាចាំបាច់ត្រូវរកជម្រើសផ្សេងទៀតដែរឬទេ? ☑ មែន

## ២. គោលបំណង

| |
|---|
| រួមចំណែកលើកទឹកចិត្តដល់អ្នកសិក្សាដែលរៀនពូកែ ជំរុញអ្នកសិក្សាដែលមានជីវភាពលំបាក និង/ឬជនជាតិដើមភាគតិចឲ្យទទួលបានការសិក្សាខ្ពង់ខ្ពស់។ |

## ៣. ជម្រើស

| |
|---|
| ១. ក្រសួងទាំងអស់បន្តអនុវត្តអនុក្រឹត្យលេខ១៨ ឆ្នាំ១៩៩៧ ទាំងអស់គ្នា។<br>២. សំណើអនុក្រឹត្យថ្មីសម្រាប់អនុវត្តចំពោះតែក្រសួងអប់រំ យុវជន និងកីឡា ចំណែកក្រសួងផ្សេងទៀត បន្តអនុវត្តអនុក្រឹត្យលេខ១៨ ឆ្នាំ១៩៩៧ ដដែល។<br>៣. អនុវត្តសំណើអនុក្រឹត្យថ្មីទាំងអស់គ្នា។ |

## ៤. ការប៉ាន់ស្មានបឋមលើចំណាយភាគពួកិច្ច និងផលប៉ះពាល់ដល់ការប្រកួតប្រជែង

៤.១. ការកំណត់ភារកិច្ច និងប្រភេទចំណាយ (tasks and cost-categories)

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១: បន្តអនុវត្តអនុក្រឹត្យលេខ១៨ ឆ្នាំ ១៩៩៧។ | -បន្ទុកចំណាយលើអាហារូបករណ៍ប្រចាំខែ<br>-បន្ទុកចំណាយលើប្រាក់ឧបត្ថម្ភអន្តេវាសិក<br>-បន្ទុកចំណាយលើប្រាក់បេសកកម្មនិងប្រាក់ស្នាក់នៅសម្រាប់មន្ត្រីរាជការចូលរួមវគ្គបំប៉នឬវិក្រឹតការ | គ្មាន |
| ជម្រើសទី២: សំណើអនុក្រឹត្យថ្មីសម្រាប់អនុវត្តចំពោះតែក្រសួងអប់រំ យុវជន និងកីឡា ចំណែកក្រសួងផ្សេងទៀត បន្តអនុវត្តអនុក្រឹត្យលេខ ១៨ ឆ្នាំ១៩៩៧។ | -បន្ទុកចំណាយលើអាហារូបករណ៍ប្រចាំខែ<br>-បន្ទុកចំណាយលើប្រាក់ឧបត្ថម្ភអន្តេវាសិក<br>-បន្ទុកចំណាយលើប្រាក់បេសកកម្មនិងប្រាក់ស្នាក់នៅសម្រាប់មន្ត្រីរាជការចូលរួមវគ្គបំប៉នឬវិក្រឹតការ | គ្មាន |
| ជម្រើសទី៣: អនុវត្តសំណើអនុក្រឹត្យថ្មីទាំងអស់គ្នា។ | -បន្ទុកចំណាយលើអាហារូបករណ៍ប្រចាំខែ<br>-បន្ទុកចំណាយលើប្រាក់ឧបត្ថម្ភអន្តេវាសិក<br>-បន្ទុកចំណាយលើប្រាក់បេសកកម្មនិងប្រាក់ស្នាក់នៅសម្រាប់មន្ត្រីរាជការចូលរួមវគ្គបំប៉នឬវិក្រឹតការ | គ្មាន |

## ៤.២. វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យ ឬប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| ជម្រើសទី១ : បន្តអនុវត្តអនុក្រឹត្យលេខ១៨ ឆ្នាំ ១៩៩៧។ | គ្មាន | គ្មាន | គ្មាន |
| ជម្រើសទី២ :សំណើអនុក្រឹត្យថ្មីសម្រាប់អនុវត្តចំពោះតែក្រសួងអប់រំ យុវជន និងកីឡា ចំណែកក្រសួងផ្សេងទៀត បន្តអនុវត្តអនុក្រឹត្យលេខ ១៨ ឆ្នាំ១៩៩៧។ | គ្មាន | គ្មាន | គ្មាន |
| ជម្រើសទី៣ : អនុវត្ត | គ្មាន | គ្មាន | គ្មាន |

| | | | |
|---|---|---|---|
| សំណើអនុក្រឹត្យថ្មីទាំងអស់គ្នា។ | | | |

## ៤.៣. ប៉ាន់ស្មានចំណាយបន្ថែមរបស់រាជរដ្ឋាភិបាល

| រាជរដ្ឋាភិបាល | | |
|---|---|---|
| ជម្រើស | កំណើនចំណាយអនុលោមតាមបញ្ញត្តិកម្ម | ផ្តល់អំណះអំណាង |
| ជម្រើសទី១ : បន្តអនុវត្តអនុក្រឹត្យលេខ១៨ ឆ្នាំ ១៩៩៧។ | មិនគួរឲ្យកត់សម្គាល់ | -បន្ទុកចំណាយចំនួន ១.៩២០.៣១៤.២០០ រៀល មានចំនួនតិចតួចបើធៀបនឹងថវិកាប្រចាំឆ្នាំសរុបទាំង៦ក្រសួង (ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) (៣.១៨២.៧៦៩,៦ លានរៀល)។<br>-បន្ទុកចំណាយនេះតិចតួច មិនសមស្របទៅនឹងការវិវត្តនៃសេដ្ឋកិច្ចជាតិ។ |
| ជម្រើសទី២ : សំណើអនុក្រឹត្យថ្មីសម្រាប់អនុវត្តចំពោះតែក្រសួងអប់រំ យុវជន និងកីឡា ចំណែកក្រសួងផ្សេងទៀត បន្តអនុវត្តអនុក្រឹត្យលេខ ១៨ ឆ្នាំ ១៩៩៧។ | មិនគួរឲ្យកត់សម្គាល់ (រាងធំជាងជម្រើសទី១) | -ក្រសួងអប់រំត្រូវចំណាយថវិកាចំនួន ៦.៣៩៧.១៩៧.២០០ រៀល បើធៀបនឹងថវិកាប្រចាំឆ្នាំ(១.៣៩២.០៤៩,0 លានរៀល) ប្រមាណ 0,0៥% ឃើញថាមានចំនួនតិចតួច។<br>-បន្ទុកចំណាយកើនឡើងពី ១.៩២០.៣១៤.២០០ រៀល (៤៨០.០៧៩ ដុល្លារ) នៃជម្រើសទី១ ទៅ ៦.៧៥១.៤២៧.២០០ រៀល (១.៦៨៧ ៨៥៧ ដុល្លារ)នៃជម្រើសទី២ មានគម្លាតប្រមាណ ៤.៨៣១.១១៣.000 រៀល (១.២០៧.៧៧៨ ដុល្លារ)។<br>-ក្រសួងការងារដែលជាក្រសួងធំទី២ បន្ទាប់ពីក្រសួងអប់រំ ក្នុងវិស័យអប់រំ បន្តអនុ |

| | | |
|---|---|---|
| | | ក្រឹត្យលេខ១៨ ឆ្នាំ១៩៩៧ រួមនឹងក្រសួងផ្សេងទៀត មិនមានបន្ទុកថវិកាធ្ងន់ធ្ងរទេ ពីព្រោះកន្លងមកក្រសួងទាំងនេះមានថវិកាគ្រប់គ្រាន់អាចទូទាត់បានជារៀងរាល់ឆ្នាំ។<br>-សិស្ស និស្សិតដែលស្ថិតនៅក្រោមក្រសួងផ្សេងទៀតនឹងមិនសប្បាយចិត្ត ដែលអាចមានហានិភ័យដល់សង្គម(មិនមានសមធម៌ក្នុងចំណោមសិស្ស និស្សិត)។ |
| ជម្រើសទី៣ : អនុវត្តសំណើអនុក្រឹត្យថ្មីទាំងអស់គ្នា។ | មិនគួរឲ្យកត់សម្គាល់ (រាងធំជាងជម្រើសទី២) | -ក្រសួងចំនួន៦ មានគ្រឹះស្ថានសិក្សា ដែលត្រូវអនុវត្តតាមស្មារតីនៃសំណើអនុក្រឹត្យថ្មីនេះ។ បើគិតពីបន្ទុកចំណាយសរុបក្នុងការអនុវត្តជម្រើសទី៣នេះ មានចំនួន ៨.៣៩៨.៣៧៧.២០០ រៀល បើធៀបនឹងថវិកាប្រចាំឆ្នាំសរុបទាំង៦ក្រសួងនេះ (៣.១៨២.៧៦៩,៦ លានរៀល) ប្រមាណ ០,០៣% ឃើញថាមានចំនួនតិចតួច។<br>-បន្ទុកចំណាយ កើនឡើងពី ១.៩២០.៣១៤.២០០ រៀល(៤៨០.០៧៩ ដុល្លារ) នៃជម្រើសទី១ ទៅ ៨.៣៩៨.៣៧៧.២០០ រៀល (២.០៨៧.០៩៤ ដុល្លារ) នៃជម្រើសទី៣។ បើធៀបនឹងជម្រើសទី២មានគម្លាត ប្រមាណ ១.៥៩៦.៩៥០.០០០ រៀល (៣៩៩ ២៣៨ ដុល្លារ)។<br>-ជម្រើសទី៣ ធៀបនឹងជម្រើសទី ២ មានគម្លាត ៣៩៩ ២៣៨ ដុល្លារ) តែប៉ុណ្ណោះ។ |

## ៤.៤. ប៉ាន់ស្មានកម្រិតនៃផលចំណេញ

| ជម្រើស | ផលចំណេញ | ផ្តល់អំណះអំណាង |
|---|---|---|
| ជម្រើសទី១ : បន្តអនុវត្ត | មិនគួរឲ្យកត់សម្គាល់ | ផលចំណេញនៃជម្រើសនេះមានកម្រិតតិច |

| | | |
|---|---|---|
| អនុក្រឹត្យលេខ១៨ ឆ្នាំ ១៩៩៧។ | | តូច។ |
| ជម្រើសទី២ : សំណើអនុក្រឹត្យថ្មីសម្រាប់អនុវត្តចំពោះតែក្រសួងអប់រំ យុវជន និងកីឡា ចំណែកក្រសួងផ្សេងទៀត បន្តអនុវត្តអនុក្រឹត្យលេខ ១៨ ឆ្នាំ១៩៩៧។ | គួរឲ្យកត់សម្គាល់ | -សិស្ស និស្សិតចំនួន១៥ ៩៧៥ នាក់ នៃក្រសួងអប់រំ យុវជន និងកីឡានឹងមានសេចក្តីរីករាយពីប្រាក់អាហារូបករណ៍ថ្មី។<br>-រួមចំណែកលើកកម្ពស់គុណភាពអប់រំ កាត់បន្ថយអត្រាបោះបង់ចោលការសិក្សា លើកទឹកចិត្តដល់អ្នកសិក្សាដែលរៀនពូកែ ជំរុញអ្នកសិក្សាដែលមានជីវភាពលំបាក និង/ឬជនជាតិដើមភាគតិចឲ្យទទួលបានការសិក្សាខ្ពង់ខ្ពស់ ដែលជាកត្តាសំខាន់មួយក្នុងការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស សំដៅកាត់បន្ថយភាពក្រីក្រ។<br>-បន្ទុកចំណាយថវិកាបន្ថែមនឹងចរាចរនៅលើទីផ្សារ បង្កើនការទិញ បង្កើនផលិតកម្ម បង្កើនការងារ រួមចំណែកជំរុញកំណើនសេដ្ឋកិច្ច។ |
| ជម្រើសទី៣ : អនុវត្តសំណើអនុក្រឹត្យថ្មីទាំងអស់គ្នា។ | គួរឲ្យកត់សម្គាល់ | ជម្រើសទី៣នេះក៏ដូចជាជម្រើសទី២ ដែរ ប៉ុន្តែវាផ្តល់ផលចំណេញច្រើនជាងជម្រើសទី២ ពីព្រោះ ៖<br>- ចំនួនសិស្សនិស្សិតទទួលបានអាហារូបករណ៍តាមរបបថ្មីមានចំនួន ២៨.០៥៤ នាក់ ច្រើនជាងជម្រើសទី២ដែលមានចំនួន១៥ ៩៧៥ នាក់។<br>-មានសមធម៌ក្នុងចំណោមសិស្សនិស្សិតនៃគ្រឹះស្ថានសិក្សាក្រោមក្រសួងនានាដែលត្រូវទទួលរបបអាហារូបករណ៍។ |

**៤.៥. តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ?**

**☑មិនមាន**

៤.៦. តើសំណើបញ្ញត្តិកម្មនេះមានផលប៉ះពាល់អវិជ្ជមានលើសមធម៌យេនឌ័រដែរឬទេ?

☑មិនមាន

## ៥. កិច្ចពិគ្រោះយោបល់

| ក្រុមអ្នកពាក់ព័ន្ធ | | វិធីសាស្ត្រ | សង្ខេបទស្សនៈ |
|---|---|---|---|
| សិស្ស និស្សិត និងបុគ្គលិកអប់រំ | សិស្ស និស្សិត និងបុគ្គលិកអប់រំ | សម្ភាសន៍ | គាំទ្រសេចក្តីព្រាងអនុក្រឹត្យថ្មី ដែលបញ្ជាក់ពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលចំពោះអ្នកសិក្សា និងមន្ត្រីរាជការ |
| រាជរដ្ឋាភិបាល | គ្រប់ក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល | កិច្ចប្រជុំអន្តរក្រសួង | មានការគាំទ្រសេចក្តីព្រាងអនុក្រឹត្យថ្មី ក៏ប៉ុន្តែ ស្នើសុំពង្រីកវិសាលភាពដល់ក្រសួង ដែលស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីអប់រំ។ |

## ៦. សន្និដ្ឋាន

៦.១. សេចក្តីសង្ខេបនៃចំណាយកាតព្វកិច្ចបន្ថែមនិងផលចំណេញ

| ជម្រើស | ចំណាយរបស់ធុរកិច្ច | ចំណាយរបស់រាជរដ្ឋាភិបាល | ផលចំណេញ |
|---|---|---|---|
| ជម្រើសទី១ : បន្តអនុវត្តអនុក្រឹត្យលេខ១៨ ឆ្នាំ១៩៩៧។ | គ្មាន | មិនគួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ |
| ជម្រើសទី២ : សំណើអនុក្រឹត្យថ្មីសម្រាប់អនុ | គ្មាន | មិនគួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ |

| | | | |
|---|---|---|---|
| វត្តចំពោះតែក្រសួងអប់រំ យុវជន និងកីឡា ចំណែកក្រសួងផ្សេងទៀត បន្តអនុវត្តអនុក្រឹត្យលេខ ១៨ ឆ្នាំ ១៩៩៧។ | | | |
| ជម្រើសទី៣ : អនុវត្តសំណើអនុក្រឹត្យថ្មីទាំងអស់គ្នា។ | គ្មាន | មិនគួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ (ផលចំណេញនៃជម្រើសទី៣នេះ មានទំហំធំជាងផចំណេញនៃជម្រើសទី២) |

## ៦.២. តើចាំបាច់ធ្វើRIS ដែរឬទេ?

☑មិនចាំបាច់

| |
|---|
| មិនចាំបាច់ធ្វើការវាយតម្លៃពេញលេញទេ(RIS) ដោយសារបន្ទុកចំណាយមានកម្រិតទាប បើធៀបនឹងថវិកាប្រចាំឆ្នាំរបស់ក្រសួងទាំងនោះ។# <br><br> # |

## ៦.៣. ជម្រើសដែលបានជ្រើសរើស

| |
|---|
| តាមការវិភាគខាងលើបង្ហាញ មានជម្រើស២ ដែលត្រូវពិចារណា ដើម្បីយកមកអនុវត្ត ក៏ប៉ុន្តែ ជម្រើសទី៣ ផ្តល់ផលចំណេញផ្នែកសេដ្ឋកិច្ច សង្គមច្រើនជាងជម្រើសទី២ បើទោះបី ជម្រើសនេះ មានបន្ទុកចំណាយច្រើនជាងគេក៏ដោយ។ ដូច្នេះ ជាអនុសាសន៍ គួរជ្រើសរើសយកជម្រើសទី៣។ <br><br> ជម្រើសដែលគួរជ្រើសរើសនេះ នឹងផ្តល់ប្រាក់អាហារូបករណ៍ និងប្រាក់ផ្សេងៗទៀត ច្រើនជាងមុន ដែលអាចឆ្លើយតបនឹងស្ថានភាពថ្លៃទំនិញនៅលើទីផ្សារបច្ចុប្បន្ន។ ម្យ៉ាងវិញទៀត ជម្រើសនេះនឹងជួយជំរុញទឹកចិត្តអ្នកសិក្សា ក្នុងការខិតខំរៀនសូត្រ កាត់បន្ថយការបោះបង់ចោលការសិក្សាក្នុងចំណោមអ្នកសិក្សាដែលមានជីវភាពក្រីក្រនិងជនជាតិដើមភាគតិច។ |

| លក្ខណវិនិច្ឆ័យ | | មូលហេតុ |
|---|---|---|
| តើវាជាជម្រើសដែលមានចំណាយកាតព្វកិច្ចបន្ថែមអប្បបរមាសម្រាប់រាជរដ្ឋាភិបាលដែរឬទេ? | មិនមែន | ជម្រើសទី៣នេះ មានបន្ទុកចំណាយបន្ថែមច្រើនជាងជម្រើសទាំង៣។ |

| | | |
|---|---|---|
| តើជម្រើសនេះផ្តល់នូវផលចំណេញអតិបរមាដែរឬទេ? | មែន | សិស្ស និស្សិតចំនួនរហូតដល់ ២៨.០៥៥៨នាក់ នឹងទទួលបានអាហារូបករណ៍ថ្មី ដែលនឹងផ្តល់ផលចំណេញដល់សង្គម និងសេដ្ឋកិច្ច ច្រើនជាងជម្រើសផ្សេងទៀត។ |

ទោះបីជាលក្ខណវិនិច្ឆ័យមួយខាងលើអវិជ្ជមាន តែការរួមបញ្ចូលគ្នានៃលក្ខណវិនិច្ឆ័យទាំងពីរមានលក្ខណៈសមស្រប។

ទោះបីជាជម្រើសនេះមានបន្ទុកចំណាយខ្ពស់ជាងគេក៏ដោយ ប៉ុន្តែផលចំណេញដែលទទួលបានក៏ខ្ពស់ជាងគេដែរ រួមមាន ៖

-ផលចំណេញផ្នែកសង្គម : ជួយដល់និស្សិតក្រីក្រ និងជាជនជាតិដើមភាគតិចឲ្យមានលទ្ធភាព និងមានឱកាសសិក្សា លើកទឹកចិត្តនិងលើកតម្កើងនិស្សិតដែលរៀនពូកែ និងជំរុញការខិតខំអភិវឌ្ឍសមត្ថភាពបន្ថែមទៀត។ រួមចំណែកលើកកម្ពស់គុណភាពអប់រំ និងកាត់បន្ថយអត្រាបោះបង់ការសិក្សា។ រួមចំណែកឲ្យសម្រេចបាននូវគោលនយោបាយនានាក្នុងវិស័យអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

-ផលចំណេញផ្នែកសេដ្ឋកិច្ច : បន្ទុកចំណាយថវិកាបន្ថែមនឹងចរាចរនៅលើទីផ្សារ បង្កើនការទិញ បង្កើនផលិតកម្ម បង្កើនការងារ រួមចំណែកជំរុញកំណើនសេដ្ឋកិច្ច។

-កញ្ចប់ចំណាយថវិការបស់រាជរដ្ឋាភិបាល ជះឥទ្ធិពលជាវិជ្ជមានទៅលើចំណាយបុគ្គល និងអាចជំរុញឲ្យមានកំណើនចំណូលជាតិសរុប។

## ៧. ការអនុវត្ត និងការតាមដាន

៧.១. តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

ក្រសួងនីមួយៗ (ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) ដែលនឹងអនុវត្តសេចក្តីព្រាងអនុក្រឹត្យថ្មីនេះ ត្រូវរៀបចំបង្កើតគណៈកម្មការ និងយន្តការបំពេញការងារ ដើម្បីសម្របសម្រួលក្នុងការអនុវត្តអនុក្រឹត្យនេះ ឲ្យស្របតាមគោលការណ៍អភិបាលកិច្ចល្អ (តម្លាភាព គណនេយ្យភាព ការចូលរួម និងការ

គោរពច្បាប់)។ ចំពោះក្រសួងណាដែលមិនទាន់បានលើកថវិកាចំណាយលើប្រាក់អាហារូបករណ៍តាមរបបថ្មីនេះសម្រាប់ឆ្នាំ២០១៧ ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើនិយ័តកម្មថវិកា។

៧.២. តើគួរធ្វើការពិនិត្យ/តាមដានបញ្ញត្តិកម្មនេះឡើងវិញក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានប្រតិបត្តិដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះគួរត្រូវបានពិនិត្យឡើងវិញ/តានដានយ៉ាងដូចម្ដេច និងនៅពេលណា?

គួរពិនិត្យបញ្ញត្តិកម្មនេះឡើងវិញរៀងរាល់ ៥ឆ្នាំម្ដង ពីព្រោះសេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជា មានការវិវត្តទៅមុខជានិច្ច ថ្លៃទំនិញតែងមានការកើនឡើង និងអំណាចទិញជាទូទៅមានការថយចុះ។

## អត្ថាធិប្បាយផ្សេងទៀត

ក្នុងករណីកំណើនសេដ្ឋកិច្ចមានកម្រិតខ្ពស់ គួរពិនិត្យពង្រីកវិសាលភាពទៅលើចំនួននិស្សិត។

| ដំណើរការ | ឈ្មោះ | មុខងារ | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|---|---|
| រៀបចំដោយ (ក្រសួងពាក់ព័ន្ធ) | លោក ស៊ិន សេងហុក | ប្រធាន RIA/MoEYS | | |
| ត្រួតពិនិត្យដោយ (ORIA) | ល.ជ ស៊ាង សុផល្លា | សមាជិក RIA | | |
| | ឯ.ឧ អេង រត្នមុនី | ប្រធានផ្នែក RIA | | |
| | ឯ.ឧ ម៉ម សារិទ្ធ | ប្រធានផ្នែក CBA | | |
| ឯកភាពដោយ (ORIA) | ឯ.ឧ ប៊ុច សុខា | ប្រធានគម្រោង | | |
| បញ្ចូលទិន្នន័យដោយ | លោក ប៉ូវ វី | អនុប្រធាន RIA/MoEYS | | |
| បញ្ចូលក្នុងគេហទំព័រដោយ | | | | |